**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ: សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-Oct-2014, 09:58
CMS/CFO: Ly Bunloung

---

**ការគាំទ្ររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅលើសំណើរបស់ សហព្រះរាជអាជ្ញាសុំចាត់តាំងក្រុមមេធាវីការពារក្តី*ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គីម ម៉េងឃី

ឡោ ជុនធី

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូរ ឧត្តរា

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

វ៉ើន ពៅ

ទី ស្រ៊ីនណា

Emmanuel ALTIT
Olivier BAHOUGNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Èlodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Michael Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN"
Mahcsh RAI
Julien RIVET
Nushin SARKARATI
Beine YE

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

## I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញា បានដាក់សំណើសុំចាត់តាំងក្រុមមេធាវីការពារក្តី *ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ[1] ជាការឆ្លើយតបទៅនឹងការចាកចេញរបស់ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ពីបន្ទប់សវនាការធំរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ក្នុងអំឡុងពេលនៃការធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ នៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២[2] និងចំពោះអវត្តមានរបស់ពួកគាត់នៅក្នុងកិច្ចប្រជុំរៀបចំសវនាការដែលប្រព្រឹត្តទៅជាបន្ទាប់មកទៀតនៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤[3]។

2. សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន បន្តធ្វើជាតំណាងឱ្យកូនក្តីរបស់ខ្លួនតទៅទៀត នៅក្នុងគ្រប់កិច្ចដំណើរការនីតិវិធីសវនាការជំនុំជម្រះក្តីទាំងអស់ និងឱ្យចូលរួមនៅក្នុងគ្រប់កិច្ចប្រជុំរៀបចំសវនាការទាំងអស់ និងព្រមានដល់ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ថា បើមានការខកខានណាមួយតទៅទៀតក្នុងការចូលរួមនៅក្នុងសវនាការរបស់តុលាការ ចាកចេញដោយពុំមានការអនុញ្ញាត ឬខកខានមិនបានតំណាងឱ្យកូនក្តីរបស់ពួកខ្លួនឱ្យអស់ពីសមត្ថភាពខាងវិជ្ជាជីវៈរបស់ខ្លួន នៅក្នុងគ្រប់ដំណើរការនីតិវិធីទាំងអស់ នឹងត្រូវបានចាត់ទុកថាជាការធ្វើឱ្យរាំងស្ទះដល់ដំណើរការនីតិវិធី តាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង ដែលអង្គជំនុំជម្រះសាលាដំបូងនឹងដាក់ទណ្ឌកម្មសមស្រប។ លើសពីនេះទៀត សហព្រះរាជអាជ្ញា ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យប្រធានអង្គភាពគាំពារការពារក្តីឱ្យរាយការណ៍ជាសម្ងាត់ជូនអង្គអង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ ស្តីពីភាពនៅទំនេរនៃមេធាវីចំនួនពីរនាក់ (ម្នាក់សម្រាប់ជនជាប់ចោទម្នាក់) ជាតិ ឬអន្តរជាតិ ដើម្បីឱ្យដើរតួនាទីជាមិត្តរបស់តុលាការ *(amici curiae)* របស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីការពារសិទ្ធិជាមូលដ្ឋានក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ក្នុងសំណុំរឿង ០០២/០២ សម្រាប់

---

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងក្រុមមេធាវីការពារក្តី *ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ (សំណៅថតចម្លងដើម្បីជាការគួរសម) ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤។

[2] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី សំណុំរឿង ០០២/០២ ឯកសារ **E1/242.1** ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤។

[3] សេចក្តីព្រាងប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤។

រយៈពេលដែលនៅសល់នៃឆ្នាំ ២០១៤។ ចុងក្រោយ សហព្រះរាជអាជ្ញា ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ណែនាំទាំងជនជាប់ចោទ និងទាំងមេធាវីការពារក្តីរបស់ពួកគេថា បើសិនជាមេធាវីការពារក្តីខកខានមិនបានចូលរួមនៅក្នុងសវនាការទាំងអស់ អង្គជំនុំជម្រះសាលាដំបូងនឹងចាត់តាំងមេធាវីឱ្យធ្វើជា *មិត្តរបស់តុលាការ* រហូតដល់ពេលណាមួយដែលមេធាវីរបស់ជនជាប់ចោទវិលត្រឡប់មកចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីវិញ ឬរហូតដល់ពេលដែលមេធាវី ត្រូវបានហាមឃាត់ លែងឱ្យចូលមកបង្ហាញខ្លួនជួសមុខឱ្យជនជាប់ចោទ ដោយសារមូលហេតុប្រព្រឹត្តកំហុសវិជ្ជាជីវៈជាបន្តបន្ទាប់។

3. នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីសវនាការសំណុំរឿង ០០២/០២ និងបន្ទាប់ពីការចាកចេញរបស់ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ពីបន្ទប់សវនាការធំ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យសហមេធាវីនាំមុខបញ្ចេញមតិយោបល់របស់ខ្លួនទៅលើការការចាកចេញនេះ។ សហមេធាវីនាំមុខអន្តរជាតិលើកឡើងថា ទោះបីជា "វាតែងតែ និងនៅតែបន្តស្ថិតក្នុងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះការគោរពសិទ្ធិខាងការពារក្តី"[4] យ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង "ត្រូវតែថ្លឹងថ្លែងឱ្យមានតុល្យភាពរវាងសិទ្ធិខាងការពារក្តី និងសិទ្ធិរបស់ជនរងគ្រោះ"[5]។ នៅក្នុងន័យនេះ សហមេធាវីនាំមុខបានបញ្ជាក់គោលជំហររបស់ខ្លួនថា "កិច្ចការយុត្តិធម៌៖ កិច្ចការយុត្តិធម៌នៅក្នុងបន្ទប់សវនាការនេះ ត្រូវតែឈានដល់ទីបញ្ចប់"[6]។

4. ដូច្នេះ សហមេធាវីនាំមុខ គាំទ្រដល់ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា ចំពោះការចាត់តាំង *មិត្តរបស់តុលាការ* និងស្នើសុំឱ្យមានដំណោះស្រាយមួយចំនួន ដូចខាងក្រោមនេះ។

## II. ច្បាប់ជាធរមាន

---

[4] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី សំណុំរឿង ០០២/០២ ឯកសារ **E1/242.1** ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ERN 01032844 បន្ទាត់ ២៤-២៥, ERN 01032845 បន្ទាត់ ១-៣ (ភាសាអង់គ្លេស)។

[5] *ដូចយោងខាងលើ* ERN 01032845 បន្ទាត់ ១៣-១៤ (ភាសាអង់គ្លេស)។

[6] *ដូចយោងខាងលើ* ERN 01032845 បន្ទាត់ ៣-៤ (ភាសាអង់គ្លេស)។

5. បន្ថែមទៅលើច្បាប់ជាធរមានដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះ សហមេធាវីនាំមុខកត់សម្គាល់ថា វិធាន ៨១(៧) នៃវិធានផ្ទៃក្នុង ផ្តល់អំណាចឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់តាំងមេធាវីនៅក្នុងស្ថានភាពជាក់លាក់មួយចំនួន។ វិធាន ៨១(៧) នៃវិធានផ្ទៃក្នុង ចែងថា ៖

> *"នៅពេលមេធាវីរបស់ជនជាប់ចោទមិនមានវត្តមានក្នុងអំឡុងពេលសវនាការ ដោយគ្មានការបញ្ជាក់អំពីមូលហេតុ អង្គជំនុំជម្រះសាលាដំបូង អាចពន្យារពេលសវនាការ ឬបើសិនជាជនជាប់ចោទស្នើសុំជំនួយមេធាវី អាចស្នើសុំឱ្យអង្គភាពគាំទ្រការការពារក្តីចាត់តាំងជាបណ្តោះអាសន្នជូនជនជាប់ចោទនោះ នូវមេធាវីដែលមានឈ្មោះក្នុងបញ្ជីដែលមានចែងក្នុងវិធាន ១១។ នៅពេលមេធាវីនោះមានពេលគ្រប់គ្រាន់ដើម្បីសិក្សាសំណុំរឿងរួចហើយ អង្គជំនុំជម្រះសាលាដំបូងបន្តសវនាការរបស់ខ្លួន"*។

6. ទោះបីជាយ៉ាងណាក៏ដោយ សហមេធាវីនាំមុខកត់សម្គាល់ថា កាលៈទេសៈនានាដែលបានរៀបរាប់នៅក្នុងវិធានផ្ទៃក្នុង មិនអាចអនុវត្តបាននៅក្នុងករណីបច្ចុប្បន្ននេះទេ ពីព្រោះជនជាប់ចោទបានណែនាំយ៉ាងច្បាស់ដល់មេធាវីរបស់ខ្លួនឱ្យធ្វើពហិការមិនចូលរួមក្នុងសវនាការលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ និងសវនាការផ្សេងៗទៀត ទាក់ទិននឹងសំណុំរឿង ០០២/០២[7]។

7. ដូច្នេះ ទម្លាប់អនុវត្ត និងនីតិវិធីដែលកំណត់យ៉ាងច្បាស់នៅក្នុងច្បាប់អន្តរជាតិ ក្នុងការចាត់តាំង *មិត្តរបស់តុលាការ* ដូចដែលបានបញ្ជាក់នៅក្នុងសារណារបស់សហព្រះរាជអាជ្ញានោះ គឺអាចយកមកអនុវត្តបានច្រើនជាង ចំពោះកាលៈទេសៈនៃកិច្ចដំណើរការនីតិវិធីទាំងនេះ[8]។ អាស្រ័យហេតុនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គាំទ្រចំពោះសំណូមពរនិងសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការចាត់តាំង *មិត្តរបស់តុលាការ* ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២។

## III. ការគាំទ្រសំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងក្រុមមេធាវីការពារក្តី *ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ

---

[7] *ដូចយោងខាងលើ* ERN 01032829 បន្ទាត់ ១៥-១៨, ERN 01032832 បន្ទាត់ ១៨-២៥ និង ERN 01032841 បន្ទាត់ ១៣-១៥ (ភាសាអង់គ្លេស)។

[8] សំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងក្រុមមេធាវីការពារក្តី *ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ (សំណៅថតចម្លងដើម្បីជាការគួរសម) ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ១៦-២០។

8. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ធ្លាប់បានលើកឡើងកាលពីមុនថា សវនាការយ៉ាងឆាប់រហ័ស គឺស្ថិតនៅក្នុងផលប្រយោជន៍នៃសុខភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៣ ដែលបានធ្វើឡើង ទាក់ទិននឹងការចាប់ផ្តើមសំណុំរឿង ០០២/០២ សហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា៖

> *"នៅពេលយើងចាប់ផ្តើមសំណុំរឿង ០០២/០២ យើងត្រូវតែធានាថា សំណុំរឿងនេះត្រូវតែដំណើរការទៅមុខឱ្យបានលឿន។ យើងមានក្តីបារម្ភដូចគ្នា ទាក់ទិននឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទ និងស្ថានភាពសុខភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនានានៅទូទាំងប្រទេស។ ដូច្នេះ វាចាំបាច់ណាស់ដែលត្រូវចាប់ផ្តើមកិច្ចដំណើរការនីតិវិធីលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ ឱ្យបានឆាប់រហ័ស"*[9] ។

9. ដើម្បីបង្ហាញអំពីតម្រូវការជាបន្តទៀតនូវសវនាការឱ្យបានឆាប់រហ័សនោះ សហមេធាវីនាំមុខសូមជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងឱ្យបានដឹង អំពីសំណើថ្មីៗនេះរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-282 ស្នើសុំដកឈ្មោះចេញពីបញ្ជីដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សម្រាប់សំណុំរឿង ០០២/០២ ដោយសារមូលហេតុជំងឺ ជាពិសេសការចងចាំរបស់ដើមបណ្តឹងរដ្ឋប្បវេណីកាន់តែធ្លាក់ចុះខ្សោយទៅៗ[10]។

10. សហមេធាវីនាំមុខ គាំទ្របន្ថែមដល់ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាដែលថា មានភាពចាំបាច់ដើម្បីធានានូវសវនាការប្រកបដោយភាពត្រឹមត្រូវ និងឆាប់រហ័ស ហើយថា ត្រូវតែមានការបង្ហាញនូវដំណោះស្រាយមួយដែលអនុញ្ញាតឱ្យសវនាការបន្តដំណើរការទៅមុខដោយគ្មានការរំខាន[11]។

---

[9] ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ ឯកសារ **E1/238.2** ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ ERN 00966159 បន្ទាត់ ១៧-២២ (ភាសាអង់គ្លេស)។

[10] សារណាជូនដំណឹងអំពីការដកដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-282 ចេញពីបញ្ជីដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងត្រូវកោះហៅឱ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (ឯកសារ E305/7.1.3) ឯកសារ **E2/40** ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ១ កថាខណ្ឌ ៥។

[11] សំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងក្រុមមេធាវីការពារក្តី *ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ (សំណៅថតចម្លងដើម្បីជាការគួរសម) ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៣ កថាខណ្ឌ ៥។

11. លើសពីនេះទៀត ការធ្វើពហិការមិនចូលរួមកិច្ចដំណើរការនីតិវិធីលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ របស់ជនជាប់ចោទ បណ្តាលឲ្យមានការពន្យារពេលបន្ថែមទៀតដែលមិនចាំបាច់ នៅក្នុងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានយុត្តិធម៌ និងសំណងការខូចខាត[12]។

12. ដូច្នេះ សហមេធាវីនាំមុខ គាំទ្រសំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងក្រុមមេធាវីការពារក្តី *ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២/០២។

## IV. **សំណូមពរ**

13. ដោយយោងទៅលើមូលហេតុដែលបានបញ្ជាក់ជូនខាងលើនេះ សហមេធាវីនាំមុខសូមស្នើឲ្យ អង្គជំនុំជម្រះសាលាដំបូង៖

ក. **បង្គាប់**ឲ្យមេធាវីរបស់ នួន ជា និង ខៀវ សំផន បន្តធ្វើជាតំណាងឲ្យកូនក្តីរបស់ខ្លួនតទៅទៀត នៅក្នុងគ្រប់កិច្ចដំណើរការនីតិវិធីសវនាការទាំងអស់ និងឲ្យចូលរួមនៅក្នុងគ្រប់សវនាការជំនុំជម្រះ និងគ្រប់កិច្ចប្រជុំរៀបចំសវនាការទាំងអស់។

ខ. **ណែនាំ** ទាំងជនជាប់ចោទ និងទាំងមេធាវីការពារក្តីរបស់ពួកគេថា បើសិនជាមេធាវីការពារក្តីខកខានមិនបានចូលរួមនៅក្នុងសវនាការណាមួយ អង្គជំនុំជម្រះសាលាដំបូងនឹងចាត់តាំងមេធាវីឲ្យធ្វើជា*មិត្តរបស់តុលាការ* ដោយឲ្យទទួលខុសត្រូវដើម្បីការពារសិទ្ធិជាមូលដ្ឋានក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ រហូតដល់ពេលណាមួយដែលមេធាវី របស់ជនជាប់ចោទវិលត្រឡប់មកចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីវិញ ឬរហូតដល់ពេលដែលមេធាវី ត្រូវបានហាមឃាត់លែងឲ្យចូលមកបង្ហាញខ្លួនជួសមុខឲ្យជនជាប់ចោទ ដោយសារមូលហេតុប្រព្រឹត្តអំពើខុសឆ្គងជាបន្តបន្ទាប់។

---

[12] សេចក្តីប្រកាសអំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម និងការរំលោភអំណាច សេចក្តីសម្រេច ៤០/៣៤ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ គោលការណ៍ ៦(ង) បញ្ជាក់ថា "ការឆ្លើយតបនៃដំណើរការផ្នែករដ្ឋបាល និងតុលាការ ទៅនឹងតម្រូវការរបស់ជនរងគ្រោះ គួរត្រូវបានសម្រួលតាមរយៈ៖ [...] ង. បញ្ចៀសមិនឲ្យមានការពន្យារពេលដែលមិនចាំបាច់ក្នុងការសម្រេចទៅលើរឿងក្តី និងការអនុវត្តដីកា ឬសេចក្តីសម្រេចផ្តល់សំណងដល់ជនរងគ្រោះ។ *ការគាំទ្ររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងក្រុមមេធាវីការពារក្តីដែលជាមិត្តរបស់តុលាការ និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ*

គ. **បង្គាប់**ឲ្យប្រធានអង្គភាពគាំពារការពារក្តី ឲ្យរាយការណ៍ជាសម្ងាត់ជូនអង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ ស្តីពីភាពនៅទំនេរនៃមេធាវីចំនួនពីរនាក់ (ម្នាក់សម្រាប់ជនជាប់ចោទម្នាក់) ដើម្បីឲ្យដើរតួនាទីជាមិត្តរបស់តុលាការ របស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីការពារសិទ្ធិជាមូលដ្ឋាន ក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ក្នុងសំណុំរឿង ០០២/០២ សម្រាប់រយៈពេលដែលនៅសល់នៃឆ្នាំ ២០១៤។

សូមលោក/លោកស្រីចៅក្រមមេត្តាទទួលយកសំណើនេះដោយសេចក្តីគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤ | ពេជ អង្គ<br><br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | |
| | Marie GUIRAUD<br><br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |